**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ៖ បព ៧២/២០២៥ កបទ.សអ

**សេចក្ដីប្រកាសព័ត៌មាន**

# លទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់នយោបាយទ្វេភាគីលើកទី៣ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និង ក្រសួងការបរទេស កំមិនវែល និងអភិវឌ្ឍន៍នៃចក្រភពអង់គ្លេស

នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ លោកជំទាវ ជ្រឹង បុទុមរង្សី រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម Dominic Williams ឯកអគ្គរាជទូត នៃចក្រភពអង់គ្លេសប្រចាំកម្ពុជា បានធ្វើជាសហប្រធាននៃកិច្ចប្រជុំពិគ្រោះយោបល់នយោបាយទ្វេភាគីលើកទី៣ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេស កំមិនវែល និងអភិវឌ្ឍន៍នៃចក្រភពអង់គ្លេសនៅទីក្រុងភ្នំពេញ។

ជាកិច្ចចាប់ផ្តើម លោកជំទាវរដ្ឋលេខាធិការបានចែករំលែកអំពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជាតិ កំណែទម្រង់ស្ថាប័ន និងវិធានការនានាដើម្បីពង្រឹងភាពធន់នៃសេដ្ឋកិច្ច ចំពេលមានបញ្ហាប្រឈម និងភាពមិនប្រាកដប្រជាជាសកល។ ឯកឧត្តមឯកអគ្គរាជទូតក៏បានផ្តល់ព័ត៌មានថ្មីៗអំពីគោលនយោបាយអាទិភាព បរិយាកាសពាណិជ្ជកម្ម និងវិនិយោគ និងការកំណត់យកវិស័យអាទិភាព ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិរបស់ចក្រភពអង់គ្លេស។

ក្នុងកិច្ចសហប្រតិបត្តិការទ្វេភាគី សហប្រធានទាំងពីរបានសម្តែងការពេញចិត្តចំពោះទំនាក់ទំនងទ្វេភាគីដែលកំពុងរីកចម្រើន និងបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាលើកកម្ពស់កិច្ចសហប្រតិបត្តិការនយោបាយ ការពារជាតិ សេដ្ឋកិច្ច ការអភិវឌ្ឍន៍ និងសន្តិសុខជាដើម។ ភាគីទាំងពីរបានគូសបញ្ជាក់ពីសារៈសំខាន់នៃការ រៀបចំកិច្ចពិគ្រោះយោបល់ជាទៀងទាត់ និងជំរុញការផ្លាស់ប្តូរទស្សនកិច្ចថ្នាក់ដឹកនាំកម្រិតខ្ពស់ ដែលរួមចំណែកពង្រឹងការជឿទុកចិត្តគ្នាទៅវិញទៅមក និងការយល់ដឹងកាន់តែស៊ីជម្រៅរវាងប្រទេសទាំងពីរ។ ចក្រភពអង់គ្លេសក៏បានកត់សម្គាល់ពីវឌ្ឍនភាពរបស់កម្ពុជាក្នុងការលើកកម្ពស់សិទ្ធិមនុស្ស។ ប្រទេសទាំងពីរក៏បានអះអាងសារជាថ្មីអំពីការប្តេជ្ញាចិត្តក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិ រួមមានការកសាងសមត្ថភាពដល់មន្ត្រី និងការបន្តរៀបចំទស្សនកិច្ចរបស់នាវាកងទ័ពជើងទឹកអង់គ្លេសមកកាន់កម្ពុជា។

ក្នុងវិស័យសេដ្ឋកិច្ច ភាគីទាំងពីរបានសម្តែងសុទិដ្ឋិនិយមអំពីការពង្រឹងទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគ ក្រោមគម្រោងពាណិជ្ជកម្មប្រទេសកំពុងអភិវឌ្ឍន៍ (DCTS) និងបានយល់ឃើញដូចគ្នាថាកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ និងឯកជនគួរតែត្រូវបានលើកកម្ពស់បន្ថែមទៀត។ ភាគីទាំងពីរទន្ទឹងរង់ចាំការរៀបចំវេទិកាពាណិជ្ជកម្ម និងវិនិយោគរួមគ្នា នៅឆ្នាំក្រោយ ខណៈឯកភាពគ្នាជំរុញការចូលរួមកាន់តែសកម្មក្នុង

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ: (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

កិច្ចសហប្រតិបត្តិការវិស័យទេសចរណ៍ ដើម្បីការរីកចម្រើនទៅវិញទៅមក និងលើកកម្ពស់ការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន។

លោកជំទាវរដ្ឋលេខាធិការបានសម្តែងអំណរគុណយ៉ាងស្មោះស្ម័គ្ររបស់កម្ពុជាចំពោះការគាំទ្រយ៉ាងសំខាន់របស់ចក្រភពអង់គ្លេស នៅក្នុងវិស័យអប់រំ ការលើកកម្ពស់សិទ្ធិអំណាចស្ត្រី កិច្ចខិតខំប្រឹងប្រែងដោះមីន ការថែទាំសុខភាព ការប្រែប្រួលអាកាសធាតុ និងតំបន់សេដ្ឋកិច្ចពិសេសបៃតងនៅកម្ពុជា។ លោកជំទាវបានបន្ថែមថា ចក្រភពអង់គ្លេសគឺជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់ដែលការគាំទ្របានផ្តល់អត្ថប្រយោជន៍ជាក់ស្តែងដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់កម្ពុជា។ ការគាំទ្រនេះត្រូវបានបង្ហាញតាមរយៈយន្តការនៃកិច្ចសហប្រតិបត្តិការ ដូចជាការផ្លាស់ប្តូរការសិក្សា និងអាហារូបករណ៍ ក៏ដូចជាគំនិតផ្តួចផ្តើមលើកកម្ពស់សមភាពយេនឌ័រ និងការលើកកម្ពស់សិទ្ធិអំណាចស្ត្រី ដែលស្តែងឱ្យឃើញតាមរយៈ កម្មវិធីក្មេងស្រីកាន់តួនាទីជំនួសកាលពី ខែតុលាកន្លងទៅ និងកម្មវិធីពានរង្វាន់ស្ត្រីផ្តើមអាស៊ីអាគ្នេយ៍ ថ្មីៗនេះនៅប្រទេសសិង្ហបុរី។ ជាការឆ្លើយតប ឯកឧត្តម ឯកអគ្គរាជទូត បានបញ្ជាក់សារជាថ្មីនូវការប្តេជ្ញារបស់ចក្រភពអង់គ្លេស ក្នុងការបន្តជួយដល់ប្រទេសកម្ពុជា លើផ្នែកដោះមីន ការអប់រំ ការថែទាំសុខភាព និងបំរែបំរួលអាកាសធាតុផងដែរ។

ភាគីទាំងពីរបានពិភាក្សាអំពីកិច្ចខិតខំប្រឹងប្រែងរួមក្នុងការប្រយុទ្ធប្រឆាំងនឹងបណ្តាញឆបោកតាមអនឡាញ ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត ស្របតាមអាទិភាពជាតិ និងកាតព្វកិច្ចអន្តរជាតិ។ ថ្នាក់ដឹកនាំទាំងពីរក៏បានសង្កត់ធ្ងន់អំពីតម្រូវការនៃការពង្រឹងកិច្ចសហប្រតិបត្តិការ និងសកម្មភាពរួមគ្នា ដើម្បីការដោះស្រាយបញ្ហាសកលទាំងនេះឱ្យមានប្រសិទ្ធភាព និងបានចែករំលែកការព្រួយបារម្ភអំពីការរីករាលដាលនៃព័ត៌មានក្លែងក្លាយ និងព័ត៌មានមិនពិត។

ភាគីទាំងពីរបានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការពហុភាគី រួមមានការគាំទ្រគ្នាទៅវិញទៅមកក្នុងវេទិកាអន្តរជាតិ និងយន្តការដើម្បីជំរុញភាពជាដៃគូសន្ទនាអាស៊ាន-ចក្រភពអង់គ្លេស ក៏ដូចជាការរំលឹកខួបលើកទី ៥ នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-ចក្រភពអង់គ្លេសនៅឆ្នាំ ២០២៦។

ភាគីទាំងពីរបានផ្លាស់ប្តូរទស្សនៈលើបញ្ហាតំបន់ និងអន្តរជាតិដែលកំពុងបន្តដែលជាកង្វល់រួម ជាពិសេសជម្លោះប្រដាប់អាវុធជាថ្មីរវាងកម្ពុជា និងថៃ ដោយកត់សម្គាល់ពីតម្រូវការបន្ទាន់ក្នុងការមានបទឈប់បាញ់ ដើម្បីសង្គ្រោះជីវិតជនស៊ីវិល និងទប់ស្កាត់ការបំផ្លិចបំផ្លាញបន្ថែមទៀត។ លោកជំទាវរដ្ឋលេខាធិការ បានរំលឹកឡើងវិញនូវការប្តេជ្ញាចិត្តយ៉ាងស្មោះស្ម័គ្រ និងឥតងាករេរបស់កម្ពុជា ក្នុងការដោះស្រាយជម្លោះដោយសន្តិវិធី និងការអនុវត្តសេចក្តីថ្លែងការណ៍រួម ដែលបានចុះហត្ថលេខានៅទីក្រុងគូឡាឡាំពួ កាលពីថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០២៥ និងបានអំពាវនាវដល់សហគមន៍អន្តរជាតិ ជំរុញឱ្យប្រទេសថៃបញ្ឈប់ការឈ្លានពានមកលើកម្ពុជា និងគោរពកិច្ចព្រមព្រៀងសន្តិភាព ហើយត្រឡប់ទៅតុចរចាវិញ។

កិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីប្រកបដោយជោគជ័យនេះបង្ហាញពីវឌ្ឍនភាពដ៏មានអត្ថន័យក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការដែលមានផលប្រយោជន៍ទៅវិញទៅមករវាងប្រទេសទាំងពីរ។ ភាគីទាំងពីរនៅតែប្តេជ្ញារក្សាការសន្ទនាជាទៀងទាត់ និងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់នយោបាយទ្វេភាគីលើកទីបួននៅទីក្រុងឡុងដ៍នៅឆ្នាំក្រោយ។

ថ្ងៃ... ១០រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៥